*មណ្ឌលអប់រំវិជ្ជាជីវៈ* **GREATER FALL RIVER**
*វិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* **DIMAN**

*<u>គោលការណ៍ស្ដីពីការអនុញ្ញាតឲ្យចូលរៀន</u>*

## I. *សេចក្ដីផ្ដើម*

*ដំណើរការនៃការអនុញ្ញាតឲ្យចូលរៀននៅសាលាវិជ្ជាជីវៈបច្ចេកទេស គឺជាការចាំបាច់ ដោយសារកន្លែងមានកំណត់ ។ ពេលជាងវិជ្ជាជីវៈបច្ចេកទេសត្រូវបានសាងសង់និងបំពាក់ឧបករណ៍ ដើម្បីបំរើសិស្សក្នុងចំនួនអតិបរិមាជាក់លាក់មួយ ។ ពេលជាងដូចនេះនិមួយៗមានលក្ខណៈឯកទេស ។ ដូចច្នេះ វិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* Diman *យើងខ្ញុំ ខ្វះខាតទាំងកន្លែង ទាំងភាពអាចបត់បែនតាមកាលៈទេសៈ ដើម្បីបំរើដល់សេចក្ដីត្រូវការ និង/ឬចំណាប់អារម្មណ៍ នៃបេក្ខជនដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការចូលរៀន ទាំងអស់ ។ ដូចច្នេះហើយ ចាំបាច់ត្រូវមានដំណើរការ<u>ជ្រើសរើស</u>មួយ ដើម្បីកំណត់យកតែបេក្ខជនដែលអាចនឹងទទួលផលច្រើនបំផុតពីឱកាសទាំងនេះ ។ បេក្ខជនដាក់ពាក្យចូលរៀនថ្នាក់ទីប្រាំបួនដល់ទីដប់ពីរទាំងអស់ នៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* Diman *នឹងត្រូវវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងគោលការណ៍ស្ដីពីការអនុញ្ញាតឲ្យចូលរៀននេះ ។ គណៈកម្មាធិការសាលានៃមណ្ឌលអប់រំវិជ្ជាជីវៈ* Greater Fall River *បានអនុម័តគោលការណ៍នេះរួចហើយ កាលពីថ្ងៃទី ៨ ខែមេសា ២០០៤ ។*

## II. *ឱកាសទទួលការសិក្សាអប់រំស្មើៗគ្នា*

*វិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* Diman *អនុញ្ញាតឲ្យសិស្សចូលរៀន ហើយផ្ដល់ឲ្យពួកគេនូវអត្ថប្រយោជន៍ សិទ្ធិ និងមុខវិជ្ជាសិក្សាទាំងឡាយ ដោយមិនរើសអើងជាតិសាសន៍ ពណ៌សំបុរ ភេទ សាសនា ដើមកំណើត ពិការភាព ឬស្នេហាផ្លូវភេទឡើយ ។*

*បើមានសិស្សណាម្នាក់មិនសូវចេះភាសាអង់គ្លេស បុគ្គលិកដែលមានសមត្ថភាពម្នាក់ពី* Diman *នឹងជួយបេក្ខជននោះក្នុងការបំពេញពាក្យសុំទាំងឡាយដែលត្រូវបំពេញ និងជួយក្នុងការបកប្រែក្នុងដំណើរការដាក់ពាក្យសុំចូលរៀនទាំងស្រុង ទៅតាមការស្នើសុំរបស់បេក្ខជននោះ ។*

*សិស្សពិការអាចប្រាប់ថាខ្លួនពិការដោយស្ម័គ្រចិត្ត ដើម្បីស្នើសុំឲ្យមានការចាត់ចែងតាមការគួរ ក្នុងដំណើរការដាក់ពាក្យសុំចូលរៀនទាំងមូល ។*

*ព័ត៌មានស្ដីពីសមត្ថភាពភាសាអង់គ្លេសទាប និងពិការភាពដាក់ជូនដោយស្ម័គ្រចិត្តដោយបេក្ខជន ដើម្បីទទួលបានជំនួយនិងការចាត់ចែងជូន ក្នុងដំណើរការដាក់ពាក្យទាំងមូល នឹងមិនប៉ះពាល់ដល់ការអនុញ្ញាតឲ្យបេក្ខជនចូលរៀននៅសាលានោះឡើយ ។*

## III. *លក្ខណៈសម្បត្តិអាចចូលរៀនបាន*

*ស្ថានភាពទីលំនៅ និងកិរិតវប្បធម៌*

សិស្សថ្នាក់ទីប្រាំបី ទីប្រាំបួន ទីដប់និងទីដប់មួយណា ដែលជាពលរដ្ឋនៃមណ្ឌលអប់រំវិជ្ជាជីវៈបច្ចេកទេសតំបន់ Greater Fall River (Fall River, Somerset, Swansea និង Westport), ដែលត្រូវដំឡើងថ្នាក់ដោយសាលាមូលដ្ឋានរបស់ខ្លួន ឲ្យចូលរៀនថ្នាក់ដែលខ្លួនចង់ចូលរៀន គឺមានសិទ្ធិដាក់ពាក្យសុំចូលរៀនខែស៊ីកឈើជ្រុះ ឬសុំចូលរៀនពាក់កណ្ដាលឆ្នាំសិក្សាបាន បើមានកន្លែងនៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ។ សិស្សដែលជាពលរដ្ឋក្នុងមណ្ឌល នឹងត្រូវវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងគោលការណ៍អនុញ្ញាតឲ្យចូលរៀននេះ ។ អាទិភាពក្នុងការអនុញ្ញាតឲ្យចូលរៀន គឺផ្ដល់ជូនទៅពលរដ្ឋក្នុងមណ្ឌលអប់រំវិជ្ជាជីវៈបច្ចេកទេសតំបន់ Greater Fall River បើតាមសេចក្ដីព្រមព្រៀងមណ្ឌល (District Agreement) ។ សិស្សដែលមិនមែនជាពលរដ្ឋនៃមណ្ឌលអប់រំវិជ្ជាជីវៈបច្ចេកទេសតំបន់ Greater Fall River មានសិទ្ធិដាក់ពាក្យសុំចូលរៀនខែស៊ីកឈើជ្រុះ ឬពាក់កណ្ដាលឆ្នាំសិក្សាបាន បើមានកន្លែងនៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman និងតែក្នុងករណីដែលសមាជិកក្នុងតារាងរង់ចាំទាំងអស់បានត្រូវអនុញ្ញាតឲ្យចូលរៀនអស់ប្រសិនបើពួកគេត្រូវដំឡើងថ្នាក់ទៅថ្នាក់ដែលពួកគេចង់ចូលរៀន ដោយសាលាមូលដ្ឋានរបស់ខ្លួន ។ សិស្សដែលមិនមែនជាពលរដ្ឋក្នុងមណ្ឌល នឹងត្រូវវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងគោលការណ៍អនុញ្ញាតឲ្យចូលរៀននេះ ។

សិស្សផ្ទេរការសិក្សាពីសាលាវិជ្ជាជីវៈបច្ចេកទេសផ្សេងទៀត មានសិទ្ធិដាក់ពាក្យសុំចូលរៀនខែស៊ីកឈើជ្រុះ ឬចូលរៀនពាក់កណ្ដាលឆ្នាំសិក្សាបាន ក្នុងថ្នាក់ទីប្រាំបួនដល់ទីដប់ពីរនៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេស Diman ប្រសិនបើពួកគេត្រូវដំឡើងថ្នាក់ទៅថ្នាក់ដែលខ្លួនចង់ចូលរៀន ដោយសាលារបស់ខ្លួនសព្វថ្ងៃ ។ សិស្សផ្ទេរការសិក្សានឹងត្រូវវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងគោលការណ៍ស្ដីពីការអនុញ្ញាតឲ្យចូលរៀននេះ ។

វិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman មិនចូលរួមក្នុងកម្មវិធីជ្រើសរើសសាលា (The School Choice Program) ឡើយ ។

សិស្សដែលត្រូវបណ្ដេញចេញពីសាលាតាមច្បាប់ M.G.L.C. 71, ផ្នែក 37H/37H ½ នៃច្បាប់ស្ដីពីកំណែទំរង់ការសិក្សាអប់រំឆ្នាំ ១៩៩៣ (Educational Reform Act of 1993) មិនមានសិទ្ធិដាក់ពាក្យសុំចូលរៀននៅសាលានេះឡើយ ។

## IV. របនាសម្ព័ន្ធចាត់ចែង

វិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman គឺជាសាលាវិជ្ជាជីវៈបច្ចេកទេសប្រចាំតំបន់របស់រដ្ឋ មានទីតាំងស្ថិតនៅបរិវេណដែលមានទេសភាពស្រស់ត្រកាលតាមដងទន្លេ Fall River, រដ្ឋ Massachusetts ។ វិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman គឺជាសមាជិកមួយនៃមណ្ឌលអប់រំវិជ្ជាជីវៈតំបន់ Greater Fall River ដែលរួមមានទីក្រុង Fall River និងទីប្រជុំជន Somerset, Swansea និង Westport ។ Diman ទទួលស្គាល់ជាផ្លូវការដោយសមាគមសាលានិងមហាវិទ្យាល័យនៃតំបន់ New England (New England Association of Schools and Colleges) និងប្ដេជ្ញាផ្ដល់កម្មវិធីវិជ្ជាជីវៈបច្ចេកទេសដែលមានគុណភាព ។

នាយកវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman មានភារៈកិច្ចមើលការខុសត្រូវលើការអនុវត្តន៍គោលការណ៍និងនីតិវិធីនានា ដែលត្រូវធ្វើឡើងដើម្បីទទួលចុះឈ្មោះបេក្ខជនឲ្យចូលរៀន ស្របតាមគោលការណ៍ស្តីពីការអនុញ្ញាតឲ្យចូលរៀននេះ ។

នាយកផ្នែកឲ្យឱវាទ (Director of Guidance) មានភារៈកិច្ចផ្សព្វផ្សាយព័ត៌មានអំពីវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman តាមរយៈការប្រជុំសាលាក្នុងមូលដ្ឋាននិងការប្រកាសព័ត៌មាន ប្រមូលពាក្យសុំចូលរៀនពីសាលានានាក្នុងមូលដ្ឋាន និងបញ្ចប់ដំណើរការចុះឈ្មោះ ។

គណៈកម្មាធិការមណ្ឌលអប់រំវិជ្ជាជីវៈតំបន់ Greater Fall River ត្រូវចុះឈ្មោះសិស្សមកពីទីប្រជុំជនដែលជាសមាជិកនានា ទាំងឡាយណាដែលខ្លួនកំណត់ថា ជាសិស្សដែលសមស្របបំផុតនឹងទទួលផលពីកម្មវិធីសិក្សានៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ។

មណ្ឌលអប់រំវិជ្ជាជីវៈបច្ចេកទេសតំបន់ Greater Fall River គ្រប់គ្រងការអនុញ្ញាតពលរដ្ឋក្នុងមណ្ឌលអប់រំឲ្យចូលរៀន ។ សេចក្តីព្រមព្រៀងមានចែងដូចខាងក្រោមៈ

> Diman នឹងចុះឈ្មោះសិស្សឲ្យចូលរៀនថ្នាក់ទីប្រាំបួន ផ្អែកលើភាគរយដូចខាងក្រោម ដូចបានចែងដោយធម្មនុញ្ញនៃចំនុះដែលអាចចុះឈ្មោះសិស្សថ្នាក់ទីប្រាំបួនដែលបានរំពឹងទុកៈ

| | |
|---|---|
| Fall River | 76.5% |
| Somerset | 9.8% |
| Swansea | 8.4% |
| Westport | 5.3% |

ក្នុងករណីដែលទីប្រជុំជនឬទីក្រុងសមាជិកណាមួយ មិនមានសិស្សគ្រប់គ្រាន់ចង់ចូលរៀននៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman កន្លែងទំនេរទាំងនោះនឹងត្រូវផ្តល់ទៅឲ្យទីប្រជុំជនឬទីក្រុងសមាជិកដទៃទៀត ផ្អែកលើភាពសមស្របបំផុតក្នុងការទទួលផលពីកម្មវិធីសិក្សាដែលផ្តល់ជូន ។ បេក្ខជនចូលរៀនថ្នាក់ទីដប់និងទីដប់មួយទាំងអស់នឹងត្រូវទទួលឲ្យចូលរៀន ផ្អែកលើភាពសមស្របបំផុតក្នុងការទទួលផលពីកម្មវិធីសិក្សាដែលមានផ្តល់ជូន ។

## V. ការជ្រើសរើសសិស្ស

1. វិទ្យាល័យវិជ្ជាជីវៈបច្ចេកទេស Diman ផ្សព្វផ្សាយព័ត៌មានអំពីសាលានេះ តាមវិធីសាស្ត្រមួយចំនួនៈ

    a. ការស្រស់ស្រូបអាហារពេលព្រឹកប្រចាំឆ្នាំមួយរបស់ក្រុមបុគ្គលិកផ្នែកឲ្យឱវាទ ដែលធ្វើឡើងដើម្បីពិនិត្យឡើងវិញនូវគោលការណ៍ស្តីពីការអនុញ្ញាតឲ្យចូលរៀននិងនីតិវិធីទាំងឡាយជាមួយបុគ្គលិកផ្នែកឲ្យឱវាទក្នុងតំបន់ ។

b. ការបញ្ចាំងវីដេអូនិងពិភាក្សាអំពីកម្មវិធីនានាដែលមានផ្តល់ជូន គឺធ្វើឡើងដោយបុគ្គលិកផ្នែកឲ្យនុវាទរបស់ Diman នៅតាមសាលានានាក្នុងមណ្ឌល នៅខែវិច្ឆិកានិងធ្នូ ។ គឺមានការពិភាក្សាអំពីឱកាសនានាសំរាប់សិស្សចង់ចាប់យកអាជីពប្លែកៗ ។

c. ដំណើរទស្សនាកម្មវិធីវិជ្ជាជីវៈតាមរូបភាព ព័ត៌មានបង្ហាញផ្លូវសិក្សា ពាក្យសុំចូលរៀន និងព័ត៌មានទាក់ទិនដទៃទៀត មានជូនតាមរយៈទំព័រវ៉ិបសៃថ៍របស់ Diman តាមអាស័យដ្ឋានៈ www.dimanregional.org

d. សិស្សមកមើលសាលានៅខែមករា នៅថ្ងៃរៀន ។ ដំណើរទស្សនារួមមាន ការបង្ហាញជូនអំពីកម្មវិធីវិជ្ជាជីវៈបច្ចេកទេសនានា រួមទាំងកម្មវិធីសិក្សា កម្មវិធីកីឡា និងកម្មវិធីក្រៅម៉ោងសិក្សានិងក្លិបផ្សេងៗទៀត ។ Diman មានដឹកសិស្សតាមរថយន្តប៊ីសរបស់សាលា ទៅកាន់វិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ។

e. នៅខែមករា មានធ្វើរាត្រីជួបជុំបេក្ខជននិងមាតាបិតា/អាណាព្យាបាលមួយ ដើម្បីផ្តល់ព័ត៌មាននិងផ្សព្វផ្សាយអំពីដំណើរការនៃការដាក់ពាក្យនិងសេវាដទៃទៀត នៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ។ បុគ្គលិករដ្ឋបាលជួបជាមួយមាតាបិតា/អាណាព្យាបាលព្រមទាំងបេក្ខជនផ្ទាល់ ម្តងម្នាក់ បន្ទាប់ពីការបង្ហាញដើម្បីឆ្លើយសំណួរនានារួចមក ។

f. កូនសៀវភៅអំពីកម្មវិធីវិជ្ជាជីវៈបច្ចេកទេស រួមទាំងកម្មវិធីសិក្សា កីឡា ការសិក្សាតាមបែបសហការ និងធនធានអប់រំពិសេសៗ នឹងមានចែកជូនក្នុងដំណើរទស្សនារបស់សិស្ស នៅពេលបើកឲ្យចូលទស្សនាសាលានៅខែមិនា និងនៅឯការបង្ហាញព័ត៌មានរបស់ការិយាល័យឲ្យនុវាទ តាមសាលានានាក្នុងមណ្ឌល ។

g. នឹងមានចុះផ្សាយការសែតអំពីសមិទ្ធិផលជាក់ស្តែងរបស់សិស្សវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ក្នុងកម្មវិធីធម្មតានិងកម្មវិធីពិសេស ការសិក្សាតាមបែបសហការ និងអំពីសាលាផ្ទាល់ជាទូទៅ ។

## IV. ដំណើរការនៃការដាក់ពាក្យ

### A. ដំណើរនៃការដាក់ពាក្យចូលរៀនថ្នាក់ទីប្រាំបួននៅខែស្លឹកឈើជ្រុះ

1. សិស្សដែលមានបំណងដាក់ពាក្យចូលរៀននៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ត្រូវៈ

a. យកពាក្យសុំមួយច្បាប់ពីបុគ្គលិកឲ្យនុវាទប្រចាំសាលារបស់ខ្លួន ពីការិយាល័យឲ្យនុវាទនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ឬពីវ៉ិបសៃថ៍ www.dimanregional.org ។

b. យកពាក្យសុំដែលបំពេញរួចនោះទៅឲ្យបុគ្គលិកឲ្យនុវាទសាលាមូលដ្ឋានវិញ តាមថ្ងៃកំណត់ ដាក់ដោយបុគ្គលិកឲ្យនុវាទនោះ ។

2. បុគ្គលិកឲ្យឱវាទសាលាមូលដ្ឋានមានភារៈកិច្ចៈ

a. បំពេញផ្នែកនៃពាក្យសុំដែលខ្លួនត្រូវបំពេញ ដែលរួមមានផ្នែកសីលធម៌ ពិន្ទុ វត្តមាននិងការផ្តល់ការគាំទ្រ ហើយបញ្ជូនទៅឲ្យផ្នែកឲ្យឱវាទនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman វិញ ឲ្យបានមុនថ្ងៃសុក្រ មុនវិស្សមកាលខែកុម្ភៈ សំរាប់ចូលរៀនខែស្ទឹកឈើជ្រុះ ។

b. សូមភ្ជាប់មកជាមួយនូវរបាយការណ៍អំពីវត្តមាននិងវិន័យរបស់សិស្ស មួយច្បាប់ ។

3. ពាក្យសុំត្រូវចាត់ទុកថាពេញលេញ នៅពេលដែលៈ

a. ព័ត៌មានចាំបាច់ទាំងអស់ត្រូវបានបំពេញនៅទំព័រទីមួយ និងទំព័រចុងក្រោយនៃពាក្យសុំ ។

b. មានហត្ថលេខាទាំងអស់ដែលតម្រូវឲ្យមាន ។

c. មានភ្ជាប់មកជាមួយនូវរបាយការណ៍អំពីវត្តមាននិងវិន័យរបស់សិស្ស ។

4. បើយើងទទួលបានពាក្យសុំដែលមិនពេញលេញ នីតិវិធីដូចខាងក្រោមនឹងត្រូវអនុវត្តៈ

a. ការិយាល័យឲ្យឱវាទនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman នឹងឲ្យដំណឹងទៅបុគ្គលិកឲ្យឱវាទនៅសាលាមូលដ្ឋានដែលទទួលខុសត្រូវក្នុងការដាក់ពាក្យនោះ ថាពាក្យសុំនោះមិនពេញលេញឡើយ ហើយសូមឲ្យបំពេញឲ្យបានពេញលេញ ។

b. មាតាបិតា/អាណាព្យាបាលសិស្សនឹងទទួលដំណឹងពីការិយាល័យឲ្យឱវាទនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ក្នុងករណីដែលបញ្ហានោះនៅមិនទាន់បានដោះស្រាយដោយបុគ្គលិកឲ្យឱវាទនៃសាលានៅមូលដ្ឋាន ។

B. ដំណើរការដាក់ពាក្យសុំចូលរៀនថ្នាក់ទីដប់ ទីដប់មួយ និងទីដប់ពីរ ដើម្បីចូលរៀនខែស្ទឹកឈើជ្រុះ:

1. សិស្សដែលមានបំណងដាក់ពាក្យចូលរៀននៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ត្រូវៈ

a. យកពាក្យសុំមួយច្បាប់ពីបុគ្គលិកឲ្យឱវាទប្រចាំសាលារបស់ខ្លួន ពីការិយាល័យឲ្យឱវាទនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ឬពីវិបសៃថ៍ www.dimanregional.org ។

b. យកពាក្យសុំដែលបំពេញរួចនោះទៅឲ្យបុគ្គលិកឲ្យឱវាទសាលាមូលដ្ឋានខ្លួនវិញ កុំឲ្យហួសថ្ងៃទី ១ ខែមិថុនា ឬ ថ្ងៃកំណត់ ដាក់ដោយបុគ្គលិកឲ្យឱវាទរបស់សិស្សនោះ ។

c. ដាក់ជូនការិយាល័យឲ្យឱវាទនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ព្រឹត្តិប័ត្រពិន្ទុចុងក្រោយមួយច្បាប់របស់ខ្លួន មិនឲ្យហួសថ្ងៃទី ១៥ ខែកក្កដា ។

2. បុគ្គលិកឲ្យនុវត្តសាលាមូលដ្ឋានមានការៈកិច្ចៈ

a. បំពេញផ្នែកនៃពាក្យសុំដែលខ្លួនត្រូវបំពេញ ហើយបញ្ជូនទៅឲ្យផ្នែកឲ្យនុវត្តនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman វិញនៅថ្ងៃចុងក្រោយនៃឆ្នាំសិក្សារបស់ខ្លួន សំរាប់ចូលរៀនខែសីហ៊ីកឈើជ្រុះ ។

b. សូមភ្ជាប់មកជាមួយនូវរបាយការណ៍អំពីវត្តមាននិងវិន័យរបស់សិស្ស មួយច្បាប់ ។

3. បើយើងទទួលបានពាក្យសុំដែលមិនពេញលេញ នីតិវិធីដូចខាងក្រោមនឹងត្រូវអនុវត្តៈ

a. ការិយាល័យឲ្យនុវត្តនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman នឹងឲ្យដំណឹងទៅបុគ្គលិកឲ្យនុវត្តនៅសាលាមូលដ្ឋានដែលទទួលខុសត្រូវក្នុងការដាក់ពាក្យនោះ ថាពាក្យសុំនោះមិនពេញលេញឡើយ ហើយសូមឲ្យបំពេញឲ្យបានពេញលេញ ។

b. មាតាបិតា/អាណាព្យាបាលសិស្សនឹងទទួលដំណឹងពីការិយាល័យឲ្យនុវត្តនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ក្នុងករណីដែលបញ្ហានោះនៅមិនទាន់បានដោះស្រាយដោយបុគ្គលិកឲ្យនុវត្តនៃសាលានៅមូលដ្ឋាន ។

c. ប្រសិនបើបន្ទាប់ពីឲ្យដំណឹងទៅបុគ្គលិកឲ្យនុវត្តសាលាមូលដ្ឋាននិងមាតាបិតា/អាណាព្យា_បាលសិស្សហើយ ពាក្យសុំនោះនៅតែមិនពេញលេញគ្រប់ដប់ (១០) ថ្ងៃរៀន ពាក្យសុំនោះនឹងចាត់ជាមោឃៈ ។

C. សិស្សផ្ទេរការសិក្សា

ពាក្យសុំពីសិស្សដែលកំពុងរៀននៅកម្មវិធីវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសអនុម័តដោយរដ្ឋ (Chapter 74) នៅសាលាណាមួយផ្សេងទៀត (សិស្សផ្ទេរការសិក្សា) នឹងទទួលការពិចារណាឲ្យចូលរៀន (រួមទាំងការអនុញ្ញាឲ្យចូលរៀននៅពាក់កណ្តាលឆ្នាំផង) ប្រសិនបើគេប្តូរទីលំនៅចេញពីសាលារបស់គេសព្វថ្ងៃ និងនៅក្នុងមណ្ឌល ហើយមានបំណងចូលរៀនក្នុងកម្មវិធីសិក្សាដូចគ្នានេះនៅឯវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ។ ពាក្យសុំរបស់ពួកគេនឹងត្រូវវាយតម្លៃ ផ្អែកតាមលក្ខណៈវិនិច្ឆ័យនៃគោលការណ៍ស្តីពីការអនុញ្ញាតឲ្យចូលរៀននេះ ។

D. សិស្សដកការសិក្សា

សិស្សដែលដកខ្លួនចេញពីវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman ហើយកំពុងរៀនឬមិនកំពុងរៀននៅវិទ្យាល័យដទៃទៀតក៏ដោយ អាចដាក់ពាក្យសុំចូលរៀនឡើងវិញ នៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់ Diman តាមនីតិវិធីដែលមានចែងក្នុងគោលការណ៍ស្តីពីការអនុញ្ញាតឲ្យចូលរៀននេះ ហើយនឹងត្រូវវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងគោលការណ៍ស្តីពីការអនុញ្ញាតឲ្យចូលរៀននេះ ។

## VII. លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស

ពាក្យសុំដែលបំពេញរួច នឹងត្រូវពិនិត្យដោយការិយាល័យឲ្យនវាទ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យក្នុងអនុញ្ញាតឲ្យចូលរៀន ដោយមានការថ្លឹងថ្លែងត្រឹមត្រូវ ។ បេក្ខជនម្នាក់ៗ នឹងត្រូវឲ្យជាពិន្ទុមួយដែលបានមកពីការសរុបពិន្ទុ នៃលក្ខណៈវិនិច្ឆ័យដូចតទៅៈ

*សីលធម៌* – អតិបរិមា 50 ពិន្ទុ

ចំពោះពាក្យសុំចូលរៀនថ្នាក់ទីប្រាំបួន ទីដប់ ទីដប់មួយ និងទីដប់ពី (ចូលរៀនខែស្ទីកឈើជ្រុះ និងចូលរៀនពាក់កណ្ដាលឆ្នាំ) សិស្សនឹងទទួលបានពិន្ទុហាសិបពិន្ទុសំរាប់សីលធម៌ល្អឥតខ្ចោះ ។ សីលធម៌ល្អឥតខ្ចោះ គឺមានន័យថា មិនធ្លាប់មានការចាប់ខ្លួន ឬការព្យួរបែបណាមួយ ។ សំរាប់ការចាប់ខ្លួនម្ដងសិស្សនឹងទទួលការដកពិន្ទុបីពិន្ទុ ហើយចំពោះការព្យួរវិញ សិស្សនឹងទទួលការដកពិន្ទុប្រាំមួយពិន្ទុ ។ របាយការណ៍អំពីវិន័យរបស់សិស្សមួយច្បាប់ត្រូវដាក់ភ្ជាប់ជាមួយពាក្យសុំ ជាចាំបាច់ ។

*ពិន្ទុរៀន* – អតិបរិមា 160 ពិន្ទុ

| មធ្យមភាគ A (100-90) | B (89-80) | C (79-70) | D (69-60) | E or F (Below 60) |
|---|---|---|---|---|
| 20 ពិន្ទុ | 15 ពិន្ទុ | 10 ពិន្ទុ | 5 ពិន្ទុ | 0 ពិន្ទុ |

ចំពោះពាក្យសុំចូលរៀនថ្នាក់ទីប្រាំបួន (ចូលរៀនខែស្ទីកឈើជ្រុះ) ពិន្ទុថ្នាក់ទីប្រាំពីរចុងក្រោយ និងពិន្ទុថ្នាក់ប្រាំបីវគ្គទី 1 និង 2 (ឬពិន្ទុត្រីមាសទីមួយ) ផ្នែកភាសាអង់គ្លេស សង្គមវិទ្យា គណិតវិទ្យា និងវិទ្យាសាស្ត្រ ស្រង់ពីព្រឹត្តិប័ត្រពិន្ទុសាលាមូលដ្ឋាន នឹងត្រូវយកមកប្រើ ។ ចំពោះពាក្យសុំចូលរៀនថ្នាក់ទីដប់ ទីដប់មួយ និងទីដប់ពីរ (ចូលរៀនខែស្ទីកឈើជ្រុះ) ពិន្ទុប្រចាំឆ្នាំនៃឆ្នាំសិក្សាពីរឆ្នាំចុងក្រោយ ផ្នែកភាសាអង់គ្លេស សង្គមវិទ្យា គណិតវិទ្យា និងវិទ្យាសាស្ត្រ ស្រង់ពីព្រឹត្តិប័ត្រពិន្ទុសាលាមូលដ្ឋាន នឹងត្រូវយកមកប្រើ ។ ចំពោះពាក្យសុំចូលរៀនថ្នាក់ ទីដប់ ទីដប់មួយ និងទីដប់ពីរ (ចូលរៀនពាក់កណ្ដាលឆ្នាំ) ពិន្ទុប្រចាំឆ្នាំឆ្នាំសិក្សាមុន ផ្នែកភាសាអង់គ្លេស សង្គមវិទ្យា គណិតវិទ្យា និងវិទ្យាសាស្ត្រ និងពិន្ទុឆ្នាំសិក្សាបច្ចុប្បន្ន គិតមកត្រឹមថ្ងៃដាក់ពាក្យ ផ្នែកភាសាអង់គ្លេស សង្គមវិទ្យា គណិតវិទ្យា និងវិទ្យាសាស្ត្រ ស្រង់ពីព្រឹត្តិប័ត្រពិន្ទុសាលាមូលដ្ឋាន នឹងយកមកប្រើ ។

*វត្តមាន* – អតិបរិមា 60 ពិន្ទុ សំរាប់ថ្នាកទី 9
អតិបរិមា 80 ពិន្ទុ សំរាប់ថ្នាកទី 10, 11 និងទី 12

| ពិន្ទុលើអវត្តមានគ្មានច្បាប់មួយឆ្នាំពេញ | ពិន្ទុលើអវត្តមានគ្មានច្បាប់សំរាប់កន្លះឆ្នាំ |
|---|---|

| | |
|---|---|
| 0 = 40 | 0 = 20 |
| 1 = 38 | 1 = 18 |
| 2 = 36 | 2 = 16 |
| 3 = 34 | 3 = 14 |
| 4 = 32 | 4 = 12 |
| 5 = 30 | 5 = 10 |
| 6 = 28 | 6 = 8 |
| 7 = 26 | 7 = 6 |
| 8 = 24 | 8 = 4 |
| 9 = 22 | 9 = 2 |
| 10 = 20 | 10 = 0 |
| 11 = 18 | |
| 12 = 16 | |
| 13 = 14 | |
| 14 = 12 | |
| 15 = 10 | |
| 16 = 8 | |
| 17 = 6 | |
| 18 = 4 | |
| 19 = 2 | |
| 20 = 0 | |

ចំពោះពាក្យសុំចូលរៀនថ្នាក់ទីប្រាំបួន (ចូលរៀនខែស៊ីកឈើជ្រុះ), អវត្តមានគ្មានច្បាប់ថ្នាក់ទីប្រាំពីរ និងវគ្គទី1 និងទី 2 ថ្នាក់ទីប្រាំបី ឬអវត្តមានគ្មានច្បាប់ក្នុងត្រីមាសទីមួយ ស្រង់ពីព្រឹត្តិប័ត្រពិន្ទុសាលាមូលដ្ឋាន នឹងត្រូវយកមកប្រើ ។ ចំពោះពាក្យសុំចូលរៀនថ្នាក់ទីដប់ ទីដប់មួយ និងទីដប់ពីរ (ចូលរៀនខែស៊ីកឈើជ្រុះ) អវត្តមានគ្មានច្បាប់ក្នុងឆ្នាំសិក្សាមុននិងឆ្នាំសិក្សាបច្ចុប្បន្ន ស្រង់ពីព្រឹត្តិប័ត្រពិន្ទុសាលាមូលដ្ឋាន នឹងត្រូវយកមកប្រើ ។ ចំពោះពាក្យសុំចូលរៀនថ្នាក់ទីដប់ ទីដប់មួយ និងទីដប់ពីរ (ចូលរៀនពាក់កណ្តាលឆ្នាំ) អវត្តមានគ្មានច្បាប់ក្នុងឆ្នាំសិក្សាមុននិងឆ្នាំសិក្សាបច្ចុប្បន្នគិតត្រឹមថ្ងៃដាក់ពាក្យ អវត្តមានស្រង់ពីព្រឹត្តិប័ត្រពិន្ទុសាលាមូលដ្ឋាន នឹងត្រូវយកមកប្រើ ។

អវត្តមានគ្មានច្បាប់ គឺជាអវត្តមានដែលសាលាមិនអនុម័ត ។ ឧទាហរណ៍ អវត្តមានអនុម័តដោយសាលា មានដូចជា: ការណាត់ជួបពេទ្យ ទៅចូលរួមបុណ្យសព ទៅបង្ហាញខ្លួននៅតុលាការ ការប្រតិបត្តិផ្នែកសាសនា ឬមូលហេតុដទៃទៀតដែលអនុម័តដោយសាលា ។ របាយការណ៍អំពីវត្តមានរបស់សិស្ស ត្រូវភ្ជាប់ជាមួយពាក្យសុំ ។

<u>ការផ្តល់ការគាំទ្រ</u> – អតិបរិមា 50 ពិន្ទុ

| ការផ្តល់ការគាំទ្រ |
|---|
| |

| |
|---|
| ផ្ដល់ការគាំទ្រយ៉ាងខ្លាំងក្លា = 50 ពិន្ទុ<br>ផ្ដល់ការគាំទ្រ = 35 ពិន្ទុ<br>ផ្ដល់ការគាំទ្រស្ទាក់ស្ទើរ = 15 ពិន្ទុ<br>មិនផ្ដល់ការគាំទ្រ = 0 ពិន្ទុ |

*ចំពោះពាក្យសុំចូលរៀនថ្នាក់ទីប្រាំបួន ទីដប់ ទីដប់មួយ និងទីដប់ពីរ (ចូលរៀនខែស៊ីកឈើជ្រុះ និងចូលរៀនពាក់កណ្ដាលឆ្នាំ) ការវាយតម្លៃរបស់បុគ្គលិកឲ្យនាំទ ទៅលើការសិក្សាជាទូទៅរបស់សិស្សនៅសាលារបស់គេ នឹងត្រូវយកមកប្រើ ក្នុងការផ្ដល់ការគាំទ្រ ។*

*បន្ទាប់ពីពិន្ទុត្រូវបានដាក់ក្នុងផ្នែកនិមួយៗរួច វាត្រូវបានបូកសរុបសំរាប់ពាក្យសុំនិមួយៗ ។ សិស្សចូលរៀនថ្នាក់ទីប្រាំបួន អាចទទួលពិន្ទុអតិបរិមាសរុបបីរយម្ភៃ(៣២០)ពិន្ទុ ហើយសំរាប់សិស្សចូលរៀនថ្នាក់ទីដប់ ទីដប់មួយ និងទីដប់ពីរ គេអាចទទួលពិន្ទុអតិបរិមាសរុបបីរយសែសិប(៣៤០)ពិន្ទុ ។*

## VIII. *ដំណើរការជ្រើសរើសសិស្ស*

*នាយកផ្នែកឲ្យនាំទនៃវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* Diman *ពិចារណាទៅលើលទ្ធផលសិក្សា វត្តមាន សីលធម៌ និងការផ្ដល់ការគាំទ្ររបស់បុគ្គលិកឲ្យនាំទ ។ ពាក្យសុំចូលរៀនត្រូវបានពិនិត្យឡើងវិញ និងឲ្យពិន្ទុតាមការកំរិតថ្នាក់ ។*

*បន្ទាប់ពីសរុបពិន្ទុសំរាប់សិស្សក្នុងមណ្ឌលម្នាក់រួចមក សិស្សក្នុងមណ្ឌលទាំងអស់ត្រូវដាក់តាមលំដាប់នៃ "ពិន្ទុសរុប" របស់គេ និងទីក្រុងដែលគេរស់នៅ ។ បន្ទាប់មក បេក្ខជនក្នុងមណ្ឌលត្រូវបានទទួលឲ្យចូលរៀន តាមលំដាប់ពិន្ទុដែលគេបានទទួល ។ បេក្ខជនក្នុងមណ្ឌលដែលបានពិន្ទុខ្ពស់ជាងគេត្រូវទទួលបានការយល់ព្រមមុនគេ បេក្ខជនដែលបានពិន្ទុខ្ពស់បន្ទាប់ ត្រូវបានទទួលការយល់ព្រមបន្ទាប់ ។ល។ និង ។ល។ រហូតដល់កន្លែងទាំងអស់ពេញ ។ បេក្ខជនក្នុងមណ្ឌលទាំងអស់ទទួលបានការយល់ព្រម ឬបដិសេធ ឬទទួលលិខិតបន្គាប់ឲ្យដាក់ព្រឹត្តិប័ត្រពិន្ទុចុងក្រោយរបស់គេ ។ បើមានកន្លែងសល់ កន្លែងទាំងនោះនឹងប្រគល់ទៅឲ្យបេក្ខជនក្នុងមណ្ឌលដែលមានលំដាប់ពិន្ទុសរុបបន្ទាប់ ។*

*ពាក្យសុំចូលរៀនដែលទទួលបានក្រោយថ្ងៃសុក្រមុនវិស្សមកាលខែកុម្ភៈ នឹងត្រូវវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យ ដូចគ្នានឹងពាក្យសុំដទៃទៀតដែរ ហើយពិន្ទុរបស់ពួកគេនឹងត្រូវដាក់បញ្ចូលតាមលំដាប់ដែលមាននៅក្នុងតារាងបេក្ខជន ។*

*បេក្ខជនទាំងអស់ដែលវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* Diman *ទទួលបានពាក្យសុំចូលរៀនមុនថ្ងៃសុក្រមុនវិស្សមកាលខែកុម្ភៈ នឹងត្រូវទទួលដំណឹងអំពីស្ថានភាពរបស់ខ្លួនតាមរយៈលិខិតផ្ញើទៅឲ្យមាតាបិតា/អាណាព្យាបាលរបស់គេ ។ បេក្ខជនដែលពាក្យសុំចូលរៀនរបស់ខ្លួនសាលាមិនបានទទួលតាមថ្ងៃកំណត់ នឹងត្រូវទទួលដំណឹងតាមលិខិតផ្ញើទៅឲ្យមាតាបិតា/អាណាព្យាបាលរបស់ពួកគេ ។*

## IX. *ការចុះឈ្មោះចូលរៀន*

*ដើម្បីចុះឈ្មោះចូលរៀននៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* Diman *នៅខែស្លឹកឈើជ្រុះបាន បេក្ខជនត្រូវតែបានដំឡើងថ្នាក់ទៅថ្នាក់ដែលគេចង់ចូលរៀន ដោយមណ្ឌលអប់រំមូលដ្ឋានរបស់ខ្លួនរួចជាមុនសិន ។ ហើយបន្ថែមលើនេះទៀត ពួកគេត្រូវតែបានប្រលងជាប់មុខវិជ្ជាភាសាអង់គ្លេស* (English Language Arts) *ឬមុខវិជ្ជាដែលមានតម្លៃស្មើគ្នា និងមុខវិជ្ជាគណិតវិទ្យា សំរាប់ឆ្នាំសិក្សាមុនចូលរៀននៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេស* Diman *។*

## X. *ការដាក់បញ្ចូលសិស្សក្នុងកម្មវិធីវិជ្ជាជីវៈបច្ចេកទេស*

*សិស្សថ្នាក់ទីប្រាំបួនទាំងអស់ដែលចុះឈ្មោះចូលរៀននៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* Diman *ចូលរួមក្នុងកម្មវិធីស្វែងយល់មួយ ដែលបង្កើតឡើងដើម្បីជួយពួកគេឲ្យយល់ដឹងអំពីទេពកោសល្យនិងចំណង់ចំណូលចិត្តរបស់ខ្លួន ទាក់ទិនទៅនឹងកម្មវិធីវិជ្ជាជីវៈបច្ចេកទេសផ្សេងៗ ។ សិស្សរាយជម្រើសកម្មវិធីស្វែងយល់បីជាចម្បងរបស់ខ្លួននៅក្នុងពាក្យសុំចូលរៀន ហើយស្វែងយល់កម្មវិធីនិមួយៗក្នុងរយៈពេលបួនទៅប្រាំថ្ងៃ ។ សិស្សត្រូវបានវាយតម្លៃនិងឲ្យពិន្ទុ* (0-100 *ពិន្ទុ*) *ដោយគ្រូបង្ហាត់នៅរោងជាងនិមួយៗ ក្នុងរយៈពេលនៃសប្តាហ៍នៅក្នុងរោងជាងនិមួយៗ ។ នៅពេលចប់ការស្វែងយល់នៅតាមរោងជាងទាំងប្រាំបីនោះរួច ថ្ងៃចុងក្រោយមុនវិសមកាលបុណ្យណូអែល សិស្សម្នាក់ៗជ្រើសរើសយកកម្មវិធីដែលខ្លួនពេញចិត្តជាជម្រើសទីមួយ ព្រមទាំងរាយជម្រើសទីពីរ ទីបី ទីបួន ទីប្រាំ និងទីប្រាំមួយ ពីរោងជាងទាំងប្រាំបី ។ សិស្សត្រូវបានទទួលឲ្យចូលរៀននៅរោងជាងដែលគេបានជ្រើសរើស ផ្អែកលើពិន្ទុសរុបដែលគេទទួលបាននៅក្នុងរោងជាងទាំងអស់ចូលគ្នា ។ ឧទាហរណ៍ៈ សិស្សម្នាក់ដែលមានពិន្ទុសរុប* 692 *នឹងទទួលការយល់ព្រមឲ្យចូលរៀន មុនសិស្សដែលបានពិន្ទុសរុប* 690 *។ បើរោងជាងណាមួយពេញ ផ្អែកលើពិន្ទុសរុប មុនពេលសិស្សទទួលបានជម្រើសទីមួយរបស់ខ្លួន នោះនាយកផ្នែកឲ្យឱវាទនឹងឲ្យសិស្សយកជម្រើសទីពីរ ទីបី ទីបួន ទីប្រាំ ឬទីប្រាំមួយរបស់គេ បើមានកន្លែងទំនេរក្នុងរោងជាង ។ ជាថ្មីម្តងទៀត សូមបញ្ជាក់ថា សិស្សត្រូវអនុញ្ញាតឲ្យចូលរៀនផ្អែកលើពិន្ទុសរុបទូទៅរបស់គេ ។ បើសិស្សណាម្នាក់បានពិន្ទុសរុបពីរោងជាងទាំងអស់ទាបពេក ដល់ថ្នាក់គេមិនអាចដាក់សិស្សនោះចូលទៅក្នុងរោងជាងណាមួយដែលគេបានជ្រើសរើស នោះនាយកផ្នែកឲ្យឱវាទនឹងដាក់សិស្សនោះទៅក្នុងរោងជាងណាមួយ ផ្អែកទៅលើកន្លែងទំនេរ លើរោងជាងដែលសិស្សបានស្វែងយល់ និងលទ្ធផលស្វែងយល់របស់សិស្ស ។ ដំណើរការនេះបន្តរហូតដល់សិស្សទាំងអស់ត្រូវបានបញ្ចូលទៅក្នុងកម្មវិធី ។*

*បើសិនជាចំនួនសិស្សចង់ចូលរៀននៅរោងជាងណាមួយច្រើនជាងចំនួនកន្លែងដែលមាននៅរោងជាងនោះ ពិន្ទុវាយតម្លៃទទួលបានដោយលំដាប់របស់សិស្ស នឹងយកមកកំណត់សិស្សដែលត្រូវដាក់ចូលរៀននៅរោងជាងណាមួយជាក់លាក់ ។*

*សិស្សដែលចង់ប្តូរពីរោងជាងមួយទៅរោងជាងមួយទៀតនៅពាក់កណ្តាលឆ្នាំសិក្សា អាចដាក់ពាក្យសុំប្តូរ ។ សំណើសុំប្តូរនឹងយកមកពិចារណា ផ្អែកទៅលើកន្លែងទំនេរដែលមាននៅក្នុងរោងជាងដែល*

*សិស្សបានស្នើ ។ បេក្ខជនសុំប្តូរម្នាក់ៗនឹងត្រូវសម្ភាសន៍និងប្រឹក្សាផ្ទាល់ ដើម្បីកំណត់ភាពសមស្របនៃការប្តូរសំរាប់សិស្សនោះ ។*

*សិស្សដែលចុះឈ្មោះចូលរៀននៅវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* Diman *ក្រោយពេលកម្មវិធីស្វែងយល់បានបញ្ចប់សព្វគ្រប់រួចហើយ នឹងត្រូវដាក់ចូលទៅក្នុងកម្មវិធីវិជ្ជាជីវៈដោយផ្ទាល់តែម្តង ។*

## XI. *ការពិនិត្យឡើងវិញ និងការតវ៉ា*

*មាតាបិតា/អាណាព្យាបាលរបស់បេក្ខជន ពេលបានទទួលលិខិតពីវិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសតំបន់* Diman *បញ្ជាក់ថាបេក្ខជនមិនត្រូវបានទទួលឲ្យចូលរៀន ឬឲ្យដាក់ព្រឹត្តិប័ត្រពិន្ទុចុងក្រោយ អាចស្នើឲ្យមានការពិនិត្យសេចក្តីសំរេចនោះឡើងវិញបាន ដោយផ្ញើលិខិតស្នើសុំឲ្យមានការពិនិត្យឡើងវិញមួយទៅកាន់នាយកសាលា ក្នុងអំឡុងពេលសាមសិបថ្ងៃនៃការទទួលលិខិត ។ នាយកសាលានឹងឆ្លើយតបជាលាយលក្ខណ៍អក្សរនូវលទ្ធផលនៃការពិនិត្យឡើងវិញនោះ ។ មាតាបិតា/អាណាព្យាលសិស្សអាចផ្ញើលិខិតស្នើសុំដាក់ពេលជួបជាមួយគណៈកម្មាធិការសាលា ដើម្បីតវ៉ាលទ្ធផលរបស់នាយកសាលានោះ ។ គណៈកម្មាធិការសាលានឹងឆ្លើយតបជាលាយលក្ខណ៍អក្សរទៅមាតាបិតា/អាណាព្យាបាល នូវថ្ងៃណាត់ជួបមួយដើម្បីធ្វើការតវ៉ា ក្នុងអំឡុងពេលសាមសិបថ្ងៃនៃការទទួលលិខិតនោះ ។ គណៈកម្មាធិការសាលានឹងឆ្លើយតបជាលាយលក្ខណ៍អក្សរចំពោះលិខិតនោះ នូវសេចក្តីសំរេចរបស់ខ្លួនលើការតវ៉ានោះ ក្នុងអំឡុងពេលសាមសិបថ្ងៃនៃការប្រជុំជាមួយគណៈកម្មាធិការសាលា នៅពេលដែលការតវ៉ានោះត្រូវបានលើកឡើង ។*

*មាតាបិតា/អាណាព្យាបាលសិស្ស ពេលបានទទួលដំណឹងពី* Diman *ថាសិស្ស/បេក្ខជនមិនត្រូវបានទទួលឲ្យចូលរៀននៅក្នុងរោងជាងណាមួយទេនោះ អាចស្នើសុំឲ្យមានការពិនិត្យឡើងវិញលើសេចក្តីសំរេចនោះ ដោយផ្ញើលិខិតសុំឲ្យមានការពិនិត្យឡើងវិញមួយ ទៅឲ្យនាយកសាលា ក្នុងអំឡុងពេលសាមសិបថ្ងៃនៃការទទួលលិខិតនោះ ។ នាយកសាលានឹងឆ្លើយតបជាលាយលក្ខណ៍អក្សរចំពោះលិខិតនោះ ជាមួយនឹងលទ្ធផលនៃការពិនិត្យឡើងវិញ ក្នុងអំឡុងពេលសាមសិបថ្ងៃ ។*